ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០
# ជម្រើសផែនទីកសិកម្ម


វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ខែធ្នូ ឆ្នាំ២០២២

ឧបត្ថម្ភបច្ចេកទេសដោយ៖ ឧបត្ថម្ភហិរញ្ញវត្ថុដោយ៖

National Institute of Statistics, Ministry of Planning, Cambodia
Food and Agriculture Organization of the United Nations
USAID FROM THE AMERICAN PEOPLE
BILL & MELINDA GATES foundation
50x2030 DATA-SMART AGRICULTURE

# មាតិកា

**បុព្វកថា** ..... i

**អារម្ភកថា** ..... iii

**ការបង្ហាញខ្លីស្តីពីវិធីសាស្ត្រអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០** ..... 1

១. គោលបំណង ..... 1

២. ទំហំនៃការអង្កេត ..... 1

៣. ពេលវេលានៃការអង្កេត និងកាលបរិច្ឆេទយោង ..... 1

៤. គ្រោងនៃការកំណត់សំណាក និងនីតិវិធីកំណត់សំណាក ..... 2

៥. វិធីសាស្ត្រអង្កេត និងប្រតិបត្តិការប្រមូលទិន្នន័យនៅវាល ..... 2

៦. ការដំណើរការទិន្នន័យ ..... 3

៧. ស្តង់ដារនៃការផ្សព្វផ្សាយទិន្នន័យ ..... 3

៨. សេចក្តីសង្ខេបសូចនាករ ..... 4

**វិធីសាស្ត្រផលិតផែនទី** ..... 5

១. គោលេបំណងនៃការផលិតផែនទី ..... 5

២. ការវាយតម្លៃតម្រូវការ ..... 5

៣. វិធីសាស្ត្រនៃការរចនាផែនទី ..... 5

# បញ្ជីផែនទី


**១. ស្ថានភាពគ្រួសារប្រកបរបរកសិកម្ម** ........ 7

ផែនទី ១.១៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត ........ 8

ផែនទី ១.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត ........ 10

**២. ស្ថានភាពកម្មសិទ្ធិលើកសិដ្ឋានរបស់គ្រួសារប្រកបរបរកសិកម្ម** ........ 13

ផែនទី ២.១៖ កម្មសិទ្ធិដីកសិកម្មផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 14

ផែនទី ២.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 16

**៣. ទំហំដីកសិកម្ម** ........ 19

ផែនទី ៣.១៖ គ្រួសារដែលមានដីកសិកម្មតិចជាង ២ ហិកតា គិតជាភាគរយ បែងចែកតាមខេត្ត ........ 20

ផែនទី ៣.២៖ គ្រួសារដែលមានដីកសិកម្មចាប់ពី ២ ដល់ក្រោម ៥ ហិកតា គិតជាភាគរយ បែងចែកតាមខេត្ត ........ 22

ផែនទី ៣.៣៖ គ្រួសារដែលមានដីកសិកម្មចាប់ពី ៥ ហិកតាឡើងទៅ គិតជាភាគរយ បែងចែកតាមខេត្ត ........ 24

**៤. ផលិតកម្មដំណាំ (រាប់ទាំងក្បាលដី និងដីជុំវិញលំនៅដ្ឋាន)** ........ 27

ផែនទី ៤.១៖ ផលិតកម្មស្រូវធម្មតានៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 28

ផែនទី ៤.២៖ អត្រាផ្ទៃដីដែលបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវធម្មតា បែងចែកតាមខេត្ត ........ 30

ផែនទី ៤.៣៖ ទិន្នផលស្រូវធម្មតា បែងចែកតាមខេត្ត ........ 32

ផែនទី ៤.៤៖ ផលិតកម្មស្រូវក្រអូបនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 34

ផែនទី ៤.៥៖ អត្រាផ្ទៃដីដែលបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវក្រអូប បែងចែកតាមខេត្ត ........ 36

ផែនទី ៤.៦៖ ទិន្នផលស្រូវក្រអូប បែងចែកតាមខេត្ត ........ 38

ផែនទី ៤.៧៖ ផលិតកម្មដំឡូងមីនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 40

ផែនទី ៤.៨៖ ទិន្នផលដំឡូងមី បែងចែកតាមខេត្ត ........ 42

ផែនទី ៤.៩៖ ផលិតកម្មពោតនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 44
ផែនទី ៤.១០៖ ទិន្នផលពោត បែងចែកតាមខេត្ត ........ 46
ផែនទី ៤.១១៖ ផលិតកម្មដំណាំស្វាយចន្ទីនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 48
ផែនទី ៤.១២៖ ផលិតកម្មដំណាំចេកនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 50
ផែនទី ៤.១៣៖ ផលិតកម្មដំណាំស្វាយនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 52

**៥. ផលិតកម្មបសុសត្វ និងបសុបក្សី ........ 55**

ផែនទី ៥.១៖ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទធំ គិតជាភាគរយ បែងចែកតាមខេត្ត ........ 56
ផែនទី ៥.២៖ ចំនួនសត្វគោសរុប បែងចែកតាមខេត្ត ........ 58
ផែនទី ៥.៣៖ ចំនួនសត្វក្របីសរុប បែងចែកតាមខេត្ត ........ 60
ផែនទី ៥.៤៖ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទតូច គិតជាភាគរយ បែងចែកតាមខេត្ត ........ 62
ផែនទី ៥.៥៖ ចំនួនសត្វជ្រូកសរុប បែងចែកតាមខេត្ត ........ 64
ផែនទី ៥.៦៖ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុបក្សី គិតជាភាគរយ បែងចែកតាមខេត្ត ........ 66

**៦. វារីវប្បកម្ម និងនេសាទ ........ 69**

ផែនទី ៦.១៖ គ្រួសារប្រកបរបរកសិកម្មមានសកម្មភាពវារីវប្បកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ........ 70
ផែនទី ៦.២៖ គ្រួសារប្រកបរបរកសិកម្មមានសកម្មភាពនេសាទ គិតជាភាគរយ បែងចែកតាមខេត្ត ........ 72
ផែនទី ៦.៣៖ ភាគរយនៃត្រីដែលនេសាទបានត្រូវបានប្រើសម្រាប់ហូបក្នុងគ្រួសារ បែងចែកតាមខេត្ត ........ 74
ផែនទី ៦.៤៖ ភាគរយនៃត្រីដែលនេសាទបានត្រូវបានលក់ បែងចែកតាមខេត្ត ........ 76

**៧. គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារប្រកបរបរកសិកម្ម ........ 79**

ផែនទី ៧.១៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាផលិតកម្មកសិកម្មគឺជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ គិតជាភាគរយ បែងចែកតាមខេត្ត ........ 80
ផែនទី ៧.២៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាផលិតកម្មកសិកម្មគឺជាចម្បងសម្រាប់លក់ គិតជាភាគរយ បែងចែកតាមខេត្ត ........ 82

**៨. សេដ្ឋកិច្ច-សង្គមរបស់គ្រួសារប្រកបរបរកសិកម្ម ........ 85**

ផែនទី ៨.១៖ គ្រួសារប្រកបរបរកសិកម្មបានធ្វើការឲ្យកសិដ្ឋានដទៃដោយប្រើប្រាស់មធ្យោបាយផលិតកម្មរបស់ខ្លួន គិតជាភាគរយ បែងចែកតាមខេត្ត ........ 86

ផែនទី ៨.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានធ្វើការងារកិនស្រូវ គិតជាភាគរយ បែងចែកតាមខេត្ត ........ 88
ផែនទី ៨.៣៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាចំណូលពីកសិកម្មរួមចំណែក ៦០%-១០០% នៃចំណូលសរុបរបស់គ្រួសារ គិតជាភាគរយ បែងចែកតាមខេត្ត ........ 90
ផែនទី ៨.៤៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាជួបគ្រោះមហន្តរាយធ្ងន់ធ្ងរយ៉ាងតិចមួយ គិតជាភាគរយ បែងចែកតាមខេត្ត ........ 92
ផែនទី ៨.៥៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយធ្ងន់ធ្ងរជាងគេ គិតជាភាគរយ បែងចែកតាមខេត្ត ........ 94
ផែនទី ៨.៦៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាទឹកជំនន់ជាគ្រោះមហន្តរាយធ្ងន់ធ្ងរជាងគេ គិតជាភាគរយ បែងចែកតាមខេត្ត........ 96
ផែនទី ៨.៧៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាគ្រោះមហន្តរាយមានកម្រិតធ្ងន់ធ្ងរជាងមុន គិតជាភាគរយ បែងចែកតាមខេត្ត ........ 98
ផែនទី ៨.៨៖ គ្រួសារប្រកបរបរកសិកម្មដែលមានសកម្មភាពកសិកម្មរងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩ គិតជាភាគរយ បែងចែកតាមខេត្ត........ 100
ផែនទី ៨.៩៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាធាតុចូលសម្រាប់ផលិតកម្មកសិកម្មមានតិចដោយសារវិបត្តិកូវីដ-១៩ គិតជាភាគរយ បែងចែកតាមខេត្ត ........ 102
ផែនទី ៨.១០៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាតម្លៃលក់ផលិតផលកសិកម្មទាបដោយសារវិបត្តិកូវីដ-១៩ គិតជាភាគរយ បែងចែកតាមខេត្ត........ 104
ផែនទី ៨.១១៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីការថយចុះនៃផលិតកម្មដំណាំដោយសារវិបត្តិកូវីដ-១៩ គិតជាភាគរយ បែងចែកតាមខេត្ត........ 106
ផែនទី ៨.១២៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីការថយចុះនៃការលក់ផលដំណាំដោយសារវិបត្តិកូវីដ-១៩ គិតជាភាគរយ បែងចែកតាមខេត្ត ........ 108
ផែនទី ៨.១៣៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាបានទទួលកម្ចីសម្រាប់ប្រើប្រាស់ក្នុងគោលបំណងធ្វើកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត........ 110

# បញ្ជីតារាង


## ១. ស្ថានភាពគ្រួសារប្រកបរបរកសិកម្ម

តារាង ១.១៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) ........ 9
តារាង ១.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) ........ 11

## ២. ស្ថានភាពកម្មសិទ្ធិលើកសិដ្ឋានរបស់គ្រួសារប្រកបរបរកសិកម្ម

តារាង ២.១៖ កម្មសិទ្ធិដីកសិកម្មផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម ........ 15
តារាង ២.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម ........ 17

## ៣. ទំហំដីកសិកម្ម

តារាង ៣.១៖ គ្រួសារដែលមានដីកសិកម្មតិចជាង ២ ហិកតា ........ 21
តារាង ៣.២៖ គ្រួសារដែលមានដីកសិកម្មចាប់ពី ២ ដល់ក្រោម ៥ ហិកតា ........ 23
តារាង ៣.៣៖ គ្រួសារដែលមានដីកសិកម្មចាប់ពី ៥ ហិកតាឡើងទៅ ........ 25

## ៤. ផលិតកម្មដំណាំ (រាប់ទាំងក្បាលដី និងដីជុំវិញលំនៅដ្ឋាន)

តារាង ៤.១៖ ផលិតកម្មស្រូវវស្សាតានៃគ្រួសារប្រកបរបរកសិកម្ម ........ 29
តារាង ៤.២៖ អត្រាផ្ទៃដីដែលបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវវស្សាតា ........ 31
តារាង ៤.៣៖ ទិន្នផលស្រូវវស្សាតា ........ 33
តារាង ៤.៤៖ ផលិតកម្មស្រូវប្រាំងនៃគ្រួសារប្រកបរបរកសិកម្ម ........ 35
តារាង ៤.៥៖ អត្រាផ្ទៃដីដែលបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវប្រាំង ........ 37
តារាង ៤.៦៖ ទិន្នផលស្រូវប្រាំង ........ 39
តារាង ៤.៧៖ ផលិតកម្មដំឡូងមីនៃគ្រួសារប្រកបរបរកសិកម្ម ........ 41
តារាង ៤.៨៖ ទិន្នផលដំឡូងមី ........ 43

តារាង ៤.៩៖ ផលិតកម្មពោត នៃគ្រួសារប្រកបរបរកសិកម្ម.......45
តារាង ៤.១០៖ ទិន្នផលពោត.......47
តារាង ៤.១១៖ ផលិតកម្មដំណាំស្វាយចន្ទីនៃគ្រួសារប្រកបរបរកសិកម្ម.......49
តារាង ៤.១២៖ ផលិតកម្មដំណាំចេកនៃគ្រួសារប្រកបរបរកសិកម្ម.......51
តារាង ៤.១៣៖ ផលិតកម្មដំណាំស្វាយនៃគ្រួសារប្រកបរបរកសិកម្ម.......53

## ៥. ផលិតកម្មបសុសត្វ និងបសុបក្សី

តារាង ៥.១៖ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទធំ.......57
តារាង ៥.២៖ ចំនួនសត្វគោសរុប.......59
តារាង ៥.៣៖ ចំនួនសត្វក្របីសរុប.......61
តារាង ៥.៤៖ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទតូច.......63
តារាង ៥.៥៖ ចំនួនសត្វជ្រូកសរុប.......65
តារាង ៥.៦៖ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុបក្សី.......67

## ៦. វារីវប្បកម្ម និងនេសាទ

តារាង ៦.១៖ គ្រួសារប្រកបរបរកសិកម្មមានសកម្មភាពវារីវប្បកម្ម.......71
តារាង ៦.២៖ គ្រួសារប្រកបរបរកសិកម្មមានសកម្មភាពនេសាទ.......73
តារាង ៦.៣៖ ភាគរយនៃត្រីដែលនេសាទបានត្រូវបានប្រើសម្រាប់ហូបក្នុងគ្រួសារ.......75
តារាង ៦.៤៖ ភាគរយនៃត្រីដែលនេសាទបានត្រូវបានលក់.......77

## ៧. គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារប្រកបរបរកសិកម្ម

តារាង ៧.១៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាផលិតកម្មកសិកម្មគឺជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ.......81
តារាង ៧.២៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាផលិតកម្មកសិកម្មគឺជាចម្បងសម្រាប់លក់.......83

## ៨. សេដ្ឋកិច្ច-សង្គមរបស់គ្រួសារប្រកបរបរកសិកម្ម

តារាង ៨.១៖ គ្រួសារប្រកបរបរកសិកម្មបានធ្វើការឲ្យកសិដ្ឋានដទៃដោយប្រើប្រាស់មធ្យោបាយផលិតកម្មរបស់ខ្លួន ........ 87
តារាង ៨.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានធ្វើការងារកិនស្រូវ........ 89
តារាង ៨.៣៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាចំណូលពីកសិកម្មរួមចំណែក ៦០%-១០០% នៃចំណូលសរុបរបស់គ្រួសារ ........ 91
តារាង ៨.៤៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាជួបគ្រោះមហន្តរាយធ្ងន់ធ្ងរយ៉ាងតិចមួយ........ 93
តារាង ៨.៥៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយធ្ងន់ធ្ងរជាងគេ ........ 95
តារាង ៨.៦៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាទឹកជំនន់ជាគ្រោះមហន្តរាយធ្ងន់ធ្ងរជាងគេ ........ 97
តារាង ៨.៧៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាគ្រោះមហន្តរាយមានកម្រិតធ្ងន់ធ្ងរជាងមុន ........ 99
តារាង ៨.៨៖ គ្រួសារប្រកបរបរកសិកម្មដែលមានសកម្មភាពកសិកម្មរងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩ ........ 101
តារាង ៨.៩៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាធាតុចូលសម្រាប់ផលិតកម្មកសិកម្មមានតិចដោយសារវិបត្តិកូវីដ-១៩........ 103
តារាង ៨.១០៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាតម្លៃលក់ផលិតផលកសិកម្មទាបដោយសារវិបត្តិកូវីដ-១៩ ........ 105
តារាង ៨.១១៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីការថយចុះនៃផលិតកម្មដំណាំដោយសារវិបត្តិកូវីដ-១៩ ........ 107
តារាង ៨.១២៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីការថយចុះនៃការលក់ផលដំណាំដោយសារវិបត្តិកូវីដ-១៩........ 109
តារាង ៨.១៣៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាបានទទួលកម្ចីសម្រាប់ប្រើប្រាស់ក្នុងគោលបំណងធ្វើកសិកម្ម ........ 111

# បុព្វកថា

ក្នុងនាមក្រសួងផែនការ និងវិទ្យាស្ថានជាតិស្ថិតិ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញនូវផែនទីដែលបានពីលទ្ធផលនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ (CAS 2020) ។ ផែនទីទាំងនេះ គឺជាសមិទ្ធិផលដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងក្នុងសកម្មភាពការងារយ៉ាងខ្លាំងពីសំណាក់មន្ត្រីជំនាញជាច្រើន និងកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងបណ្តាក្រសួងសាមីពាក់ព័ន្ធ រដ្ឋបាលគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ និងប្រជាជនកម្ពុជានៅក្នុងរាជធានីខេត្តទាំង២៥។

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ គឺជាសមិទ្ធិផលដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជួយឲ្យស្វែងយល់កាន់តែប្រសើរអំពីស្ថានភាពកសិកម្ម ជួយដល់ការសម្រេចចិត្តដោយផ្អែកលើព័ត៌មាន និងជាធាតុចូលដ៏រឹងមាំសម្រាប់ការរៀបចំគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មឲ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពថែមទៀត។ ផែនទីទាំងឡាយនៅក្នុងរបាយការណ៍នេះនឹងបង្ហាញនូវសកម្មភាពនិងជីវភាពរបស់គ្រួសារកសិករកម្ពុជា។ តាមរយៈ ផែនទីទាំងនេះ យើងនឹងយល់ដឹងបន្ថែមអំពីស្ថានភាពស្របច្បាប់នៃគ្រួសារដែលកាន់កាប់ដីកសិកម្ម ស្ថានភាពកាន់កាប់ដី ការដាំដុះដំណាំ បសុសត្វ បសុបក្សី និងវារីវប្បកម្មនៅក្នុងខេត្តទាំងអស់ ភាពរងគ្រោះទៅនឹងគ្រោះមហន្តរាយដូជាទឹកជំនន់ និងគ្រោះរាំងស្ងួតរបស់គ្រួសារកសិករ ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ទៅលើសកម្មភាពកសិកម្ម ទិដ្ឋភាពសេដ្ឋកិច្ច ព្រមទាំងលក្ខណៈសេដ្ឋកិច្ចមួយចំនួនរបស់គ្រួសារប្រកបរបរកសិកម្មនៅក្នុងប្រទេសកម្ពុជា។

ព័ត៌មានលម្អិតបន្ថែមមាននៅក្នុងតារាងទិន្នន័យ និងក្រាហ្វិចដែលភ្ជាប់មកជាមួយផែនទីនីមួយៗនៅក្នុងរបាយការណ៍នេះ និងនៅក្នុងរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ចុងក្រោយ។ យើងចែករំលែកព័ត៌មានទាំងនេះដោយឥតគិតថ្លៃ ដោយសង្ឃឹមថាការវិនិយោគទៅលើអង្កេតកសិកម្មនិងការផលិតផែនទីនេះនឹងផ្តល់នូវអត្ថប្រយោជន៍ត្រឡប់វិញបានច្រើនបំផុត។ អត្ថប្រយោជន៍ទាំងនោះគឺពាក់ព័ន្ធនឹងការគ្រប់គ្រងដីនិងធនធាននានារបស់យើងប្រកបដោយនិរន្តរភាព សន្តិសុខស្បៀង ការទទួលផលចំណេញ និងផលិតភាពកសិកម្ម ព្រមទាំងជីវភាពរបស់ប្រជាជននៅជនបទ។ ឯកសារផែនទីនេះ ជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ធ្វើការវាស់វែងការប្រែប្រួលនៅក្នុងវិស័យកសិកម្ម និងនៅក្នុងជីវភាពរបស់គ្រួសារកសិករនៅតាមជនបទ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែផ្តល់ការគាំទ្រចំពោះសកម្មភាពការងារស្ថិតិ ដែលនាំឲ្យសម្រេចបាននូវការបញ្ចប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០នេះ ប្រកបដោយលទ្ធផលផ្លែផ្កា គុណភាព ប្រសិទ្ធភាព ទាន់ពេលវេលាសម្រាប់បំពេញសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ។ ខ្ញុំសូមថ្លែងអំណរគុណដល់ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដល់នាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ដល់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ប្រចាំនៅកម្ពុជា ដែលបានចូលរួមជួយសម្របសម្រួលធ្វើសកម្មភាពការងារអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០នេះ រហូតដល់ទីបញ្ចប់ទទួលបានជោគជ័យជាស្ថាពរ។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់អង្គការ FAO និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានគាំទ្រផ្តល់មូលនិធិ និងជំនួយបច្ចេកទេស។ ការជួយគាំទ្រនេះមានសារៈសំខាន់ណាស់ចំពោះភាពជោគជ័យនៃការផលិតនិងចងក្រងផែនទីអំពីកសិកម្មនេះ និងបានជួយលើកកម្ពស់សមត្ថភាពមន្ត្រី រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តសកម្មភាពអង្កេតកសិកម្ម ឬអង្កេតដ៏ទៃទៀតស្រដៀងគ្នានេះនាពេលអនាគត។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ **ឯកឧត្តម ហោ ដារិទ្ធ** រដ្ឋលេខាធិការនៃក្រសួងផែនការ ទទួលបន្ទុកអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ និង **លោកជំទាវ ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងក្រុមការងារបច្ចេកទេសទាំងអស់ពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងពីនាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានដឹកនាំធ្វើសកម្មភាពអង្កេត និងវិភាគរបាយការណ៍លទ្ធផលទិន្នន័យអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ និងសូមអរគុណដល់អ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមចំណែកក្នុងការងារផលិតផែនទីនេះឲ្យសម្រេចបានជោគជ័យប្រកបដោយគុណភាព ប្រសិទ្ធភាព និងបានទាន់ពេលវេលា សម្រាប់តម្រូវការចាំបាច់របស់អ្នកប្រើប្រាស់ដែលកើនឡើងជាលំដាប់។

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែធ្នូ ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

នាងខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានបង្ហាញផែនទីទិន្នន័យអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ដោយមានកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ពីអង្គការស្បៀង និងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO) សម្រាប់ចងក្រងឯកសារផែនទីដើម្បីជាប្រយោជន៍ដលអ្នករៀបចំផែនការនិងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម បរិស្ថាន និងអ្នកស្រាវជ្រាវទាំងក្នុងនិងក្រៅប្រទេស ឬរាជរដ្ឋាភិបាល អង្គការជាតិ និអង្គការអន្តរជាតិ។

វិទ្យាស្ថានជាតិស្ថិតិបានធ្វើអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ជាលើកដំបូង បន្ទាប់ពីបានធ្វើជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១៣ ដើម្បីប្រមូលទិន្នន័យស្តីពី ស្ថានភាពនិងរចនាសម្ព័ន្ធនៃវិស័យកសិកម្ម លក្ខណៈនៃគ្រួសារកសិករ លំនាំនៃផលិតកម្ម និងប្រព័ន្ធផលិកម្មកសិកម្មនៅទូទាំងប្រទេសកម្ពុជា។ ក្រោយពីធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិបន្តធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ដែលផ្តល់ព័ត៌មានដ៏មានតម្លៃសម្រាប់ការរៀបចំគោលនយោបាយ និងសម្រាប់តាមដានការអភិវឌ្ឍនៅក្នុងវិស័យកសិកម្ម។ ព័ត៌មានអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០នេះ ត្រូវបានសង្ឃឹមថានឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាទាក់ទឹងនឹងមូលដ្ឋានធនធាន ប្រព័ន្ធផលិតកម្មកសិកម្ម និងស្ថានភាពសេដ្ឋកិច្ចសង្គមនៃគ្រួសារនៅជនបទ។ វានឹងធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងអំពីកសិកម្មនៅប្រទេសកម្ពុជា និងជួយតម្រង់ទិសយុទ្ធសាស្ត្រជាតិដើម្បីបង្កើនផលិតភាពកសិកម្ម ដែលនឹងធានាបាននូវនិរន្តរភាពជីវភាពជនបទ សន្តិសុខភាព និងការពារធនធានធម្មជាតិសម្រាប់ពេលអនាគត។

ការផលិតកម្រងផែនទីតាមប្រធានបទស្តីពីកសិកម្មកម្ពុជាឆ្នាំ២០២០ គឺជាសមិទ្ធិផលដ៏សំខាន់មួយទៀតរបស់កម្ពុជា បន្តពីឆ្នាំ២០១៩។ របាយការណ៍នេះចងក្រងផែនទីចំនួន ៤៥ និងក្រាហ្វិកដែលឆ្លើយតបនឹងផែនទីទាំងនោះ ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃគ្រួសារកាន់កាប់កសិកម្ម កម្មសិទ្ធិដីកសិកម្ម លំនាំនៃផលិតកម្ម ភាពរងគ្រោះទៅនឹងគ្រោះមហន្តរាយ ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ទៅលើសកម្មភាពកសិកម្មកម្ពុជា។

ការផលិតផែនទីទាំងនេះគឺផ្តើមចេញពីមតិរបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្មដែលចង់ឲ្យមានការផលិតធនធានព័ត៌មានដែលងាយស្រួលមើល និងមានប្រយោជន៍ចេញពីទិន្នន័យអង្កេតកសិកម្ម។ ទិដ្ឋភាពផ្នែកទីតាំងមួយចំនួនគឺត្រូវបានបង្ហាញយ៉ាងងាយ និងច្បាស់នៅក្នុងផែនទីតាមប្រធានបទទាំងនេះ ដែលអាចឲ្យស្វែងយល់កាន់តែប្រសើរអំពីធនធាន លំនាំនៃផលិតកម្ម និងស្ថានភាពសេដ្ឋកិច្ចសង្គម នៅក្នុងវិស័យកសិកម្មនៅក្នុងគ្រួសារជនបទ។ ព័ត៌មានទាំងនេះមានបញ្ចូលយ៉ាងទូលំទូលាយនៅក្នុងរបាយការណ៍ចុងក្រោយនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ហើយទិន្នន័យអាចត្រូវបានស្វែងយល់កាន់តែស៊ីជម្រៅ និងលម្អិតនៅក្នុងឯកសាបោះពុម្ព និងតាមគេហទំព័ររបស់វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ។

ជាទីបញ្ចប់ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ការសហការគាំទ្រដល់ដំណើរការងារអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០នេះ។ នាងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោក លោកស្រី ទាំងអស់នៃក្រុមការងារស្នូលនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ មកពីវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជំនាញការនៃអង្គការ

ស្បៀង និងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO) ព្រមទាំងមន្ត្រីទាំងអស់ដែលបានចូលរួមអនុវត្តការងារប្រមូល វិភាគទិន្នន័យ ចងក្រងរបាយការណ៍ចុងក្រោយ របាយការណ៍ផែនទីកសិកម្ម រហូតសម្រេចបានជោគជ័យ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ព្រមទាំងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានផ្តល់មូលនិធិគាំទ្រដល់អង្កេតកសិកម្មកម្ពុជានេះ។

នាងខ្ញុំសង្ឃឹមថា របាយការណ៍ផែនទីនេះនឹងក្លាយជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំកម្មវិធីគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឲ្យកាន់តែមានគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ របាយការណ៍ផែនទីនេះត្រូវបានបើកចំហសម្រាប់ពិភាក្សា ព្រមទាំងទទួលនូវរាល់មតិយោបល់ ឬអនុសាសន៍ សម្រាប់កែលម្អ អភិវឌ្ឍន៍របាយការណ៍ និងលទ្ធផលវិភាគទិន្នន័យឲ្យកាន់តែល្អថែមទៀតនាពេលអនាគត។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក**
**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហង់ លីណា**

# ការបង្ហាញខ្លីស្ដីពីវិធីសាស្ត្រអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ (CAS 2020) គឺជាការអង្កេតទូលំទូលាយដើម្បីប្រមូល និងចងក្រងព័ត៌មានស្ដីពី ការដាំដុះដំណាំ ការចិញ្ចឹមសត្វនិងបសុបក្សី វារីវប្បកម្ម និងនេសាទ ព្រមទាំងទិដ្ឋភាពសេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធ។ ទិន្នន័យដែលបានពីអង្កេតនេះនឹងមានប្រយោជន៍ក្នុងការរៀបចំបង្កើតផែនការ គោលនយោបាយ និងកម្មវិធីសម្រាប់អភិវឌ្ឍ និងកែលម្អវិស័យកសិកម្មនិងនេសាទ របស់រាជរដ្ឋាភិបាលកម្ពុជា។ CAS 2020 ត្រូវបានធ្វើឡើងបន្តពីអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ (CIAS 2019) និងជំរឿនកសិកម្មលើកទីមួយរបស់កម្ពុជានៅឆ្នាំ២០១៣។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាក្រសួងសាមីមានភារកិច្ចទទួលខុសត្រូវលើការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០នេះ។ ទន្ទឹមនឹងនេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានតួនាទីនិងភារកិច្ចក្នុងការធ្វើអង្កេត ចងក្រង វិភាគរបាយការណ៍លទ្ធផលអង្កេតកសិកម្ម រីឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ទិន្នន័យអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០។

## ១. គោលបំណង

គោលបំណងចម្បងនៃ CAS 2020 គឺដើម្បីផ្ដល់ទិន្នន័យស្ដីពីស្ថានភាពកសិកម្មនាពេលបច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជា ដែលអ្នកធ្វើផែនការ អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកដើរតួនាទីសំខាន់ក្នុងវិស័យកសិកម្ម អាចយកទៅប្រើប្រាស់បាន។ ទិន្នន័យ CAS 2020 នឹងមានប្រយោជន៍នៅក្នុង៖

1) ការផ្ដល់គ្រោងនៃការកំណត់សំណាកដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់អនុវត្តនៅក្នុងការអង្កេតកសិកម្មនានា
2) ការផ្ដល់ទិន្នន័យនៅកម្រិតជាតិ តំបន់ និងខេត្ត
3) ការផ្ដល់ទិន្នន័យស្ដីពីរចនាសម្ព័ន្ធបច្ចុប្បន្ននៃគ្រួសារកសិកម្មនៅកម្ពុជា ដែលរួមមានការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វនិងបសុបក្សី និងសកម្មភាពវារីវប្បកម្ម និងការនេសាទ ព្រមទាំងស្ថានភាពសេដ្ឋកិច្ចសង្គមដែលពាក់ព័ន្ធរបស់គ្រួសារប្រកបរបរកសិកម្ម។

## ២. ទំហំនៃការអង្កេត

CAS 2020 បានប្រើប្រាស់កម្រងសំណួរតែមួយប៉ុណ្ណោះ ដែលប្រមូលព័ត៌មានអំពីទិដ្ឋភាពមួយចំនួននៃគ្រួសារប្រកបរបរកសិកម្ម ដែលរួមមានព័ត៌មានអំពីប្រជាសាស្ត្រនៃម្ចាស់កាន់កាប់កសិកម្ម និងសហកម្មសិទ្ធិករនៃការកាន់កាប់ ព្រមទាំងសមាជិកក្នុងគ្រួសារទាំងអស់ អំពីសកម្មភាពផលិតកម្មដំណាំ ការចិញ្ចឹមបសុសត្វ ការចិញ្ចឹមបសុបក្សី ការចញ្ចឹមសត្វល្អិត សកម្មភាពវារីវប្បកម្ម សកម្មភាពនេសាទ សកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេល១២ខែចុងក្រោយ។ កម្រងសំណួរនេះក៏ប្រមូលព័ត៌មានអំពីផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ទៅលើគ្រួសារប្រកបរបរកសិកម្ម កម្លាំងពលកម្មដែលត្រូវបានប្រើប្រាស់អ្នកកាន់កាប់កសិកម្ម និងទិន្នន័យដែលបង្ហាញនូវកម្រិតនៃការជួបប្រទះអសន្តិសុខស្បៀងរបស់គ្រួសារប្រកបរបរកសិកម្ម។

## ៣. ពេលវេលានៃការអង្កេត និងកាលបរិច្ឆេទយោង

CAS 2020 ត្រូវបានធ្វើឡើងជាមួយដំណាក់កាល ដោយសារតែវាបានប្រើប្រាស់សំណាក់ដូចគ្នានឹង CIAS 2019 (longitudinal design)។ ការអង្កេតទៅលើគ្រួសារប្រកបរបរកសិកម្ម ត្រូវបានធ្វើឡើងស្របគ្នាជាមួយនឹងការសម្ភាសន៍សហគ្រាសកសិកម្មខ្នាតធំ ចាប់ពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១។ រយៈពេល ១២ ខែ គិតមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ (មានន័យថាពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ទៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០) ត្រូវបានប្រើប្រាស់ជារយៈពេលយោងសម្រាប់ការប្រមូលទិន្នន័យ។

## ៤. គ្រោងនៃការកំណត់សំណាក និងនីតិវិធីកំណត់សំណាក

ដោយសារតែបរិបទវិបត្តិជំងឺកូវីដ-១៩ សំណាកសម្រាប់ CIAS 2019 ត្រូវបានសម្រេចឲ្យប្រើសម្រាប់ CAS 2020 ដោយក្រុមការងារអង្កេត។ ទោះបីជាមានការថយចុះចំនួនសំណាកដោយសារតែគ្រួសារមួយចំនួនបានផ្លាស់ទីលំនៅ ឬឈប់ធ្វើសកម្មភាពកសិកម្មក៏ដោយ ក៏វិធីសាស្ត្រនេះនៅតែអនុញ្ញាតឲ្យប្រមូលទិន្នន័យបានគ្រប់គ្រាន់ ដើម្បីសង្ខេបនៅក្នុងកម្រិតប្រទេស និងកម្រិតតំបន់ ជាមួយនឹងអញ្ញត្តិជាច្រើននឹងនៅកម្រិតខេត្តផងដែរ។

វិធីសាស្ត្រសម្រាប់ CIAS 2019 រួមមានការជ្រើសរើសសំណាកតំណាងនៅក្នុងមណ្ឌលអង្កេត (Enumeration Area) នៅទូទាំងប្រទេសកម្ពុជា ដែលបានពីគ្រោងកំណត់សំណាកនៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣។ នៅក្នុងមណ្ឌលអង្កេតទាំងនេះ គ្រួសារដែលមានសកម្មភាពកសិកម្មត្រូវបានជ្រើសរើស។ ដោយប្រើប្រាស់ព័ត៌មានជាមូលដ្ឋាននេះ គ្រួសារប្រកបរបរកសិកម្មត្រូវបានបែងចែក (stratified) និងជ្រើសរើសជាសំណាកសម្រាប់ការប្រមូលទិន្នន័យ។ គ្រួសារដែលត្រូវបានសម្ភាសន៍កាលពី CIAS 2019 ក៏ត្រូវបានទាក់ទងដើម្បីធ្វើការសម្ភាសន៍សម្រាប់ CAS 2020 នេះផងដែរ។

គ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជា លើកលែងតែគ្រួសារនៅក្នុងខណ្ឌឬសង្កាត់ទាំងឡាយដែលនៅកណ្ដាលទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងក្រុងសៀមរាប អាចមានលទ្ធភាពដែលត្រូវបានជ្រើសរើសនៅក្នុងសំណាកនៃ CIAS 2019 និងដូចគ្នានៅក្នុង CAS 2020 នេះ។ សំណាកនៃ CAS 2020 គឺមាន ១៥,៩៨២ គ្រួសារប្រកបរបរកសិកម្ម ដែលបានសម្ភាសន៍កាលពី CIAS 2019។

បន្ថែមលើការប្រមូលទិន្នន័យពីគ្រួសារប្រកបរបរកសិកម្ម ការប្រមូលទិន្នន័យពីសហគ្រាសកសិកម្មខ្នាតធំដែលគ្រប់គ្រងដោយក្រុមហ៊ុន សហករណ៍ ស្ថាប័នរដ្ឋនិងឯកជនក៏ត្រូវបានធ្វើឡើងផងដែរ។ ទិន្នន័យត្រូវបានប្រមូលពីសហគ្រាសកសិកម្មខ្នាតធំចំនួន ១៩៧។

## ៥. វិធីសាស្ត្រអង្កេត និងប្រតិបត្តិការប្រមូលទិន្នន័យនៅវាល

ទិន្នន័យទាំងអស់ក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០នេះ ត្រូវបានប្រមូលតាមរយៈការសម្ភាសផ្ទាល់ដោយមានជំនួយពីប្រព័ន្ធកុំព្យូទ័រ (CAPI) ដោយក្រុមអ្នកប្រមូលទិន្នន័យដែលបានទទួលការបណ្ដុះបណ្ដាល និងអ្នកត្រួតពិនិត្យ ដែលធ្វើការសម្ភាសន៍ផ្ទាល់ជាមួយអ្នកឆ្លើយតបដែលមានការយល់ដឹងអំពីការកាន់កាប់កសិកម្ម។ ការប្រើប្រាស់ CAPI សម្រាប់ការប្រមូលទិន្នន័យ ជួយដល់ការត្រួតពិនិត្យតាមដានលំហូរទិន្នន័យ និងគុណភាពទិន្នន័យទាន់ពេលវេលា។ អ្នកឆ្លើយតបគឺជាមនុស្សពេញវ័យដែលមានចំណេះដឹងអំពីសកម្មភាពនៃការកាន់កាប់កសិកម្ម។ អ្នកឆ្លើយតបដែលមានគុណវុឌ្ឍិបំផុតគឺអ្នកកាន់កាប់កសិកម្ម។ ប៉ុន្តែ នៅពេលបុគ្គលទាំងនេះមិននៅ ប្ដី/ប្រពន្ធ ឬសមាជិកគ្រួសារដែលមានការយល់ដឹង ក៏អាចជាអ្នកឆ្លើយតបដែរ។ គ្មានការសម្ភាស ឬសាកសួរព័ត៌មានអំពីការកាន់កាប់កសិកម្មដែលស្ថិតក្នុងការអង្កេត ពីអ្នកជិតខាង ឬគ្រួសារផ្សេងទៀតនោះទេ។

ទិន្នន័យទាំងអស់ពីអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ត្រូវបានប្រមូលដោយអ្នកប្រមូលទិន្នន័យដែលត្រូវបានជ្រើសរើសពីមន្ត្រីថ្នាក់ជាតិនិងថ្នាក់ខេត្តនៃវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រតិបត្តិការនៅវាលរួមមាន ការបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យនិងអ្នកត្រួតពិនិត្យទាំងអស់ ការប្រមូលទិន្នន័យនិងការត្រួតពិនិត្យ។

អ្នកត្រួតពិនិត្យទិន្នន័យដែលជាមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិ ទទួលខុសត្រូវលើការពិនិត្យការគ្រប់គ្រងគុណភាពទិន្នន័យ។ អ្នកត្រួតពិនិត្យនៅមូលដ្ឋាន ដែលមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិទ្យាស្ថានជាតិស្ថិតិ ទទួលខុសត្រូវលើការជួយដល់មន្ត្រីប្រមូលទិន្នន័យតាមមូលដ្ឋាន ដោយជម្រុញឲ្យមានទំនាក់ទំនងល្អជាមួយអ្នកភូមិ និងបង្កើនកិច្ចសហប្រតិបត្តិការពីអ្នកឆ្លើយតបការសម្ភាសដែលមកពីគ្រួសារកាន់កាប់កសិកម្ម។ មន្ត្រីសរុប ៤៦០ នាក់បានចូលរួមក្នុងការប្រមូលទិន្នន័យនេះ។

## ៦. ការដំណើរការទិន្នន័យ

នៅពេលមន្ត្រីសម្ភាសន៍ បានប្រមូលទិន្នន័យអង្កេតសម្រាប់គ្រួសារកសិកម្មមួយរួចរាល់ ពួកគេបានផ្ញើកម្រងសំណួរដែលបានបំពេញនោះតាមរយៈកម្មវិធី Survey Solutions ទៅកាន់មន្ត្រីត្រួតពិនិត្យទិន្នន័យរបស់ពួកគេ ដែលមន្ត្រីត្រួតពិនិត្យនោះធ្វើការត្រួតពិនិត្យកម្រងសំណួរដែលបានបំពេញរួចនោះ។ ប្រសិនបើមានកំហុស ឬទិន្នន័យគួរឲ្យសង្ស័យ មន្ត្រីត្រួតពិនិត្យនឹងផ្ញើត្រឡប់វិញនូវកំណត់ត្រានោះមន្ត្រីសម្ភាសន៍ ដើម្បីដោះស្រាយបញ្ហានោះជាមួយអ្នកឆ្លើយតបប្រសិនបើចាំបាច់ ហើយកំណត់ត្រាដែលបានកែតម្រូវរួចនឹងត្រូវបានផ្ញើម្តងទៀតទៅកាន់មន្ត្រីត្រួតពិនិត្យទិន្នន័យ។ នៅពេលកំណត់ត្រាត្រូវបានផ្ទៀតផ្ទាត់ដោយមន្ត្រីត្រួតពិនិត្យទិន្នន័យរួចហើយ ត្រូវផ្ញើកំណត់ត្រានោះទៅមន្ត្រីថ្នាក់កណ្តាល ដើម្បីសុំការឯកភាពជាចុងក្រោយ។ នៅការិយាល័យអង្កេតថ្នាក់កណ្តាល កម្រងសំណួរបំពេញរួចត្រូវបានទទួលបន្ទាប់ពីត្រូវបានឯកភាពដោយមន្ត្រីត្រួតពិនិត្យទិន្នន័យ។ ប្រសិនបើរកឃើញបញ្ហា ឬទិន្នន័យដែលគួរឲ្យសង្ស័យក្នុងអំឡុងពេលត្រួតពិនិត្យនៅថ្នាក់កណ្តាល កំណត់ត្រាអាចត្រូវបានបញ្ជូនត្រឡប់វិញទៅកាន់អ្នកប្រមូលទិន្នន័យសម្រាប់ធ្វើការផ្ទៀតផ្ទាត់ ឬកែតម្រូវប្រសិនបើចាំបាច់។ ការពិនិត្យទិន្នន័យឡើងវិញ និងការគណនាតួលេខប៉ាន់ប្រមាណរបស់ការអង្កេតត្រូវបានធ្វើឡើងដោយប្រើប្រាស់កម្មវិធី R Studio។ ការផ្ទៀងផ្ទាត់ទិន្នន័យចាប់ផ្តើមតាំងពីនៅពេលកម្រងសំណួរត្រូវបានតាក់តែងនៅក្នុងឧបករណ៍ CAPI ពីព្រោះកម្មវិធី Survey Solutions អនុញ្ញាតឲ្យមានការពិនិត្យភាពស៊ីសង្វាក់ ដើម្បីដាក់បញ្ចូលទៅក្នុងឧបករណ៍ប្រមូលទិន្នន័យ។ នៅពេលកំណត់ត្រាបំពេញរួចត្រូវបានបញ្ជូនត្រឡប់មកវិញក្នុងដំណាក់កាលប្រមូលទិន្នន័យ ការពិនិត្យភាពស៊ីសង្វាក់បន្ថែមទៀតត្រូវបានធ្វើឡើងដោយប្រៀបធៀបរបាយការណ៍ទៅនឹងទិន្នន័យជំរឿនពីមុន ដោយវាយតម្លៃលើភាពសមហេតុផល សម្រាប់ចំណុចដាក់លាក់ និងផ្ទៀងផ្ទាត់លើតួលេខឯកត្តៈខ្វាតជាមួយមន្ត្រីសម្ភាសន៍ និង/ឬ អ្នកផ្តល់ចម្លើយ។

## ៧. ស្តង់ដារនៃការផ្សព្វផ្សាយទិន្នន័យ

ចំនួនគ្រួសារត្រូវបានបង្គត់ត្រឹមខ្ទង់ពាន់ ទៅតាមវិធាននៃការបង្ហាញទិន្នន័យដូចក្នុងរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០។ ភាគរយ/ផលធៀប ត្រូវបានគណនាដោយប្រើតម្លៃបង្គត់ទាំងនេះ។ ក្រាហ្វិក និងផែនទីនៅក្នុងរបាយការណ៍នេះប្រើប្រាស់តម្លៃបង្គត់ទាំងនេះ។ នៅក្នុងតារាងទិន្នន័យនៅក្នុងរបាយការណ៍នេះ សញ្ញា (-) ត្រូវបានប្រើនៅពេលដែលចំនួននៃការអង្កេតស្មើសូន្យឬតិចពេក នៅពេលដែលចំនួនគ្រួសារដែលបានបង្គត់រួចមិនស្មើ១០០០គ្រួសារ ឬនៅពេលដែលមានតម្លៃ Coefficient of Variation (CV) ធំជាងឬស្មើ៣៣។ លើសពីនេះ ទិន្នន័យមួយចំនួននៅក្នុងតារាងអាចនឹងមានសញ្ញា (-) ជាការមិនបង្ហាញទីពីរ។ ខេត្តដែលមានសញ្ញា (-) ត្រូវបានកំណត់សម្គាល់ក្នុងផែនទីថា "Not Available"។

## ៨. សេចក្តីសង្ខេបសូចនាករ

ការប៉ាន់ស្មានសំខាន់ៗមួយចំនួនដែលទទួលបានពីការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ មានបង្ហាញក្នុងតារាងខាងក្រោមសម្រាប់ប្រទេសកម្ពុជាទាំងមូល៖

| | |
|---|---|
| **សង្ខេបសូចនាករ៖ ការកាន់កាប់កសិកម្មតាមគ្រួសារ** | |
| ចំនួនគ្រួសារកាន់កាប់កសិកម្ម | ២.០៣៨.០០០ |
| **ភាគរយនៃគ្រួសារកាន់កាប់កសិកម្ម ធ្វើកសិកម្មក្នុងគោលបំណងចម្បង៖** | |
| សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ | ៦១,០% |
| សម្រាប់ការលក់ | ៣៩,០% |
| **សកម្មភាពផលិតកម្មដំណាំ** | |
| ចំនួនគ្រួសារដែលដាំដុះដំណាំ | ១.៩២០.០០០ |
| ភាគរយនៃចំនួនគ្រួសារដែលដាំដុះដំណាំ | ៩៤,២% |
| **សកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី និង/ឬ សត្វល្អិត** | |
| ចំនួនគ្រួសារដែលចិញ្ចឹមបសុសត្វ បសុបក្សី និង/ឬ សត្វល្អិតនៅក្នុងអំឡុងឆ្នាំយោង | ១.៦៧០.០០០ |
| ភាគរយនៃគ្រួសារដែលចិញ្ចឹមបសុសត្វ បសុបក្សី និង/ឬ សត្វល្អិតនៅក្នុងអំឡុងឆ្នាំយោង | ៨១,៩% |
| **សកម្មភាពវារីវប្បកម្ម និងនេសាទ** | |
| ចំនួនគ្រួសារដែលចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង/ឬ នេសាទ | ៦៣៨.០០០ |
| ភាគរយនៃគ្រួសារដែលចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង/ឬ នេសាទ | ៣១,៣% |
| **ក្នុងចំណោមគ្រួសារដែលចូលរួមសកម្មភាពវារីវប្បកម្ម និង/ឬ នេសាទ** | |
| ភាគរយនៃគ្រួសារដែលចូលរួមតែក្នុងសកម្មភាពវារីវប្បកម្ម ពីចំនួនគ្រួសារសរុបដែលចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង/ឬ នេសាទ | ១៣,០% |
| ភាគរយនៃគ្រួសារដែលចូលរួមតែក្នុងសកម្មភាពនេសាទ ពីចំនួនគ្រួសារសរុបដែលចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង/ឬ នេសាទ | ៨០,៤% |
| ភាគរយនៃគ្រួសារដែលចូលរួមទាំងក្នុងសកម្មភាពវារីវប្បកម្មនិងនេសាទ ពីចំនួនគ្រួសារសរុបដែលចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង/ឬ នេសាទ | ៦,៦% |
| **សេដ្ឋកិច្ចរបស់គ្រួសារប្រកបរបរកសិកម្ម** | |
| ចំនួនគ្រួសារដែលរាយការណ៍ថា៦០%-១០០%នៃចំណូលសរុបរបស់គ្រួសារបានមកពីចំណូលកសិកម្ម | ៤១៤.០០០ |
| ភាគរយនៃគ្រួសារដែលរាយការណ៍ថា៦០%-១០០%នៃចំណូលសរុបរបស់គ្រួសារបានមកពីចំណូលកសិកម្ម | ២០,៣% |
| ចំនួនគ្រួសារដែលបានរងគ្រោះមហន្តរាយធ្ងន់ធ្ងរយ៉ាងហោចណាស់ម្តង | ៨១០.០០០ |
| ភាគរយនៃគ្រួសារដែលបានរងគ្រោះមហន្តរាយធ្ងន់ធ្ងរយ៉ាងហោចណាស់ម្តង | ៣៩,៨% |

# វិធីសាស្ត្រផលិតផែនទី

## ១. គោលបំណងនៃការផលិតផែនទី

សកម្មភាពផលិតផែនទីត្រូវបានធ្វើឡើងពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១ ក្រោយពីបញ្ចប់ការវិភាគទិន្នន័យអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០។ គោលបំណងសំខាន់នៃសកម្មភាពនេះគឺដើម្បីផលិតកម្រងផែនទីតាមប្រធានបទដោយប្រើលទ្ធផលអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០បែងចែកតាមខេត្ត និងដែលត្រូវបានគិតថាមានប្រយោជន៍បំផុតដោយដៃគូរដ្ឋាភិបាល។

ការផលិតផែនទីដែលបង្ហាញសូចនាករដែលពាក់ព័ន្ធនឹងកសិកម្ម នៅថ្នាក់ជាតិត្រូវបានរំពឹងថានឹងផ្តល់ជាមូលដ្ឋានព័ត៌មានដល់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីអំពីនិន្នាការ និងបម្រែបម្រួលនៅក្នុងប្រទេសកម្ពុជា ព្រមទាំងនឹងជួយតម្រង់ទិសគោលនយោបាយ និងកម្មវិធីអភិវឌ្ឍថ្មីៗ។ គោលបំណងបន្ទាប់បន្សំនៃសកម្មភាពនេះគឺដើម្បីបង្ហាញ និងធ្វើផែនទីសេដ្ឋកិច្ចសង្គមរបស់កម្ពុជានៅក្នុងវិស័យកសិកម្ម ស្របទៅតាមទិន្នន័យដែលមាន។

## ២. ការវាយតម្លៃតម្រូវការ

អ្នកជំនាញផ្នែកប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ថ្នាក់ជាតិ បានសហការជាមួយអ្នកជំនាញមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ FAO ដើម្បីកំណត់រកវិធីសាសាស្ត្រសមស្របបំផុត ដើម្បីជ្រើសរើសផែនទីដែលពាក់ព័ន្ធ និងមានប្រយោជន៍បំផុត ហើយបន្ទាប់មកធ្វើការរចនាផែនទីទាំងនោះ។ ការវាយតម្លៃតម្រូវការនេះត្រូវបបានធ្វើឡើងក្នុងទម្រង់ជាកិច្ចប្រជុំជាមួយតំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីសម្រេចជាចុងក្រោយនូវបញ្ជីនៃផែនទីតាមប្រធានបទដែលត្រូវផលិត។

## ៣. វិធីសាស្ត្រនៃការរចនាផែនទី

ផែនទីតាមប្រធានបទ (Thematic maps) អាចហៅថា ផែនទីសម្រាប់គោលបំណងពិសេស ផែនទីផ្តោតលើប្រធានបទតែមួយ ឬផែនទីស្ថិតិ។ ផែនទីតាមប្រធានបទផ្តោតលើបម្រែបម្រួលទីតាំងនៃរបាយទិន្នន័យ ឬប្រធានបទណាមួយ (ដូចជា ដំណាំ បសុសត្វ ឬផលធៀបផ្ទៃដីប្រមូលផលទៅនឹងផ្ទៃដីដាំដុះ)។ ជាធម្មតា ផែនទីតាមប្រធានបទ រួមបញ្ចូលនូវព័ត៌មានទីតាំង ឬព័ត៌មានយោង ដូចជាចំណងជើងផែនទី ឈ្មោះទីកន្លែង ឬផ្ទៃទឹកសំខាន់ៗ មាត្រដ្ឋាន ព្រួញចង្អុលទិសខាងជើង និងសញ្ញាសម្គាល់ ដើម្បីជួយឲ្យអ្នកមើលផែនទីយល់ពីតំបន់ភូមិសាស្ត្រនៅលើផែនទី។ ផែនទីតាមប្រធានបទទាំងអស់មានធាតុសំខាន់ៗពីរគឺៈផែនទីគោល និងទិន្នន័យស្ថិតិ។ ធាតុទាំងពីរនេះជាធម្មតាមានទម្រង់ជាហ្វាលឌីជីថល (digital files) ដូចជាហ្វាលព្រំប្រទល់រដ្ឋបាល និងហ្វាលទិន្នន័យជំរឿនឬទិន្នន័យអង្កេត។

ផែនទីតាមប្រធានបទ បង្ហាញទិន្នន័យស្តីពីប្រធានបទមួយ ស្ថិតនៅក្នុងព្រំប្រទល់នៃតំបន់ភូមិសាស្ត្រដែលបានជ្រើសរើស ដូចជាក្នុងករណីនេះគឺខេត្ត។ ជាធម្មតា ទិន្នន័យទាំងនេះត្រូវបានបែងចែកជាថ្នាក់នៃតម្លៃមួយចំនួន និងត្រូវបានដាក់និមិត្តសញ្ញាដោយប្រើពណ៌ខុសៗគ្នាដើម្បីតំណាងឲ្យថ្នាក់នីមួយៗ។ ផែនទីតាមប្រធានបទ គឺជាជំនួយក្នុងការមើលដ៏មានប្រសិទ្ធភាពសម្រាប់បង្ហាញទិន្នន័យសហគមន៍តាមបែប អព្ភន្តញាណ ជាពិសេសសម្រាប់អ្នកដែលមិនមានជំនាញក៏អាចយល់បាន។

ផែនទីអាចបង្ហាញយ៉ាងលឿននូវលំនាំឬបណ្តុំភូមិសាស្ត្រនៃកិសកម្មគ្រួសារ កសិកម្មសេដ្ឋកិច្ច ដំណាំ ព្រៃឈើ ជលផល ធនធានក្នុងសហគមន៍ ដែលសំខាន់សម្រាប់ជួយដល់ដំណើរការធ្វើផែនការរួម។ នៅពេលត្រូវបានផលិតរួច ផែនទីគឺងាយស្រួលប្រើឡើងវិញក្នុងទម្រង់ជាច្រើន។ ផែនទីអាចត្រូវបានប្រើក្នុងបទបង្ហាញ ឯកសារបោះពុម្ពផ្សេងៗ និងនៅលើគេហទំព័រ។ ផែនទីក៏អាចត្រូវបានប្រើជាបទជំនួយសម្រាប់បទបង្ហាញក្នុងកិច្ចប្រជុំសាធារណៈផងដែរ។ ការប្រើផែនទីក្នុងកិច្ចប្រជុំសាធារណៈជួយឲ្យទស្សនិកជនឃើញទិន្នន័យដែលមាន តំបន់គោលដៅដែលស្នើឡើង និងតម្រូវការផ្សេងទៀតរបស់សហគមន៍ក្នុងទម្រង់ជារូបភាព។

បច្ចេកវិទ្យាប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងបោះពុម្ពនៅលើកុំព្យូទ័រត្រូវបានប្រើដើម្បីផលិតផែនទីតាមប្រធានបទទាំងនេះ។ ផែនទីនៅក្នុងរបាយការណ៍នេះត្រូវបានផលិតឡើងដោយប្រើប្រាស់កម្មវិធី QGIS Version 3.16 ដែលជាកម្មវិធីបើកចំហនិងឥតគិតថ្លៃ។ ប្រព័ន្ធផលិតផែនទីស្វ័យប្រវត្តិត្រូវបានបង្កើតឡើងដើម្បីផលិតហ្វាលផែនទីឌីជីថល (digital map files) ដោយផ្អែកលើទិន្នន័យស្ថិតិពីអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០។ ប្រព័ន្ធនេះប្រើប្រាស់ហ្វាលទិន្នន័យស្ថិតិកសិកម្ម និងហ្វាលព្រំប្រទល់ខេត្ត ដើម្បីផលិតផែនទីពណ៌ទៅតាមប្រធានបទ។ កម្មវិធី QGIS ធ្វើប្រតិបត្តិការគូសផែនទីដែលរួមមាន ការបែងចែកទិន្នន័យជាថ្នាក់ផ្សេងៗ ការដាក់និមិត្តិសញ្ញា(ពណ៌) ទៅអោយថ្នាក់ទាំងនេះ ការបង្កើតនិងកំណត់ទីតាំងចំណងជើងផែនទី សញ្ញាសម្គាល់ កំណត់ចំណាំ មាត្រដ្ឋាន និងព្រួញទិសខាងជើង ព្រមទាំងការបំលែងផែនទីឲ្យទៅជាហ្វាលរូបភាពឌីជីថល។ ពណ៌សម្រាប់ផែនទីតាមប្រធានបទនីមួយៗត្រូវបានជ្រើសរើសពីពណ៌ដែលមានស្រាប់នៅក្នុងកម្មវិធីQGIS ដោយមានការកែប្រែបន្តិចបន្តួចនៅកន្លែងដែលចាំបាច់ដើម្បីផែនទីកាន់តែងាយស្រួលមើល។ ខេត្តដែលមានសញ្ញា (-) នៅក្នុងតារាងទិន្នន័យត្រូវបានដាក់កំណត់សម្គាល់ថា "Not Available" នៅលើផែនទី។

ទិន្នន័យស្ថិតិ និងព្រំប្រទល់ខេត្តត្រូវបានកំណត់អត្តសញ្ញាណដោយលេខកូដខេត្ត ដែលអនុញ្ញាតភ្ជាប់ទំនាក់ទំនងមួយទល់មួយ រវាងទិន្នន័យស្ថិតិ និងព្រំប្រទល់ខេត្ត។ ផែនទីតាមប្រធានបទទាំងអស់ត្រូវបានផលិតនៅមាត្រដ្ឋាន ១:២.៥០០.០០០ និងស្ថិតនៅក្នុងចំណោលផែនទី UTM (Zone 48N) ជាមួយនឹងជាទុម Indian 1960។

- <u>*ប្រភពទិន្នន័យផែនទីគោល*</u>៖ ផែនទីតាមប្រធានបទទាំងអស់ត្រូវបានរចនាដោយប្រើប្រាស់ផែនទីគោលដូចគ្នា ដែលបង្ហាញព្រំប្រទល់ជាមួយប្រទេសជិតខាង (រួមទាំងកោះនានា) ព្រំប្រទល់ខេត្ត និងផ្ទៃទឹក។ ផែនទីគោលទាំងនេះត្រូវបានផលិតដោយស្ថាប័នផ្លូវការ ដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ និងវិទ្យាស្ថានជាតិស្ថិតិ។
- <u>*ប្រភពទិន្នន័យសម្រាប់ផលិតផែនទីតាមប្រធានបទ*</u>៖ រាល់ទិន្នន័យដែលបង្ហាញក្នុងផែនទីតាម្របធានបទនេះ ប្រើប្រាស់តារាងទិន្នន័យដែលបានពីការវិភាគទិន្នន័យអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ដោយមិនមានការកែប្រែ។ នៅពេលចាំបាច់ ការគណនាបន្ថែមត្រូវបានធ្វើឡើងពីទិន្នន័យដើម។

# ១. ស្ថានភាពគ្រួសារប្រកបរបរកសិកម្ម

# ផែនទី ១.១៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត

**កម្ពុជា**

ចំនួនគ្រួសារប្រកបរបរកសិកម្មសរុប : ២.០៣៨.៤៣៥

ភាគរយនៃចំនួនគ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) : ៨២,៣%




គ្រួសារប្រកបរបរកសិកម្មភាគច្រើននៅកម្ពុជា បានរាយការណ៍ឯកកម្មសិទ្ធិ(មិនបានចុះបញ្ជី)។ ក្នុងខេត្តចំនួន១១នៃខេត្តទាំង២៥ លើស ៩០% នៃគ្រួសារប្រកបរបរកសិកម្ម បានរាយការណ៍ពីឯកកម្មសិទ្ធិមិនបានចុះបញ្ជី ខណៈដែលនៅខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងខេត្តប៉ៃលិន មានតិចជាង ៥០%។

## កំណត់សម្គាល់

ផ្ទៃទឹក

គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) (%)

- ៤០,០ - ៥០,០
- ៥០,១ - ៧០,០
- ៧០,១ - ៩០,០
- > ៩០,០

ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

តារាង ១.១៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី)

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) | គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) (%) |
|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ៤៧.០០០ | ៤២,៣ |
| ០២ | បាត់ដំបង | ៧៧.០០០ | ៥៥,៤ |
| ០៣ | កំពង់ចាម | ៦៣.០០០ | ៤៥,៧ |
| ០៤ | កំពង់ឆ្នាំង | ៨៣.០០០ | ៩៣,៣ |
| ០៥ | កំពង់ស្ពឺ | ១០៧.០០០ | ៨៩,២ |
| ០៦ | កំពង់ធំ | ១០៩.០០០ | ៩១,៦ |
| ០៧ | កំពត | ១០៨.០០០ | ៩៨,២ |
| ០៨ | កណ្ដាល | ១២៩.០០០ | ៩៧,៧ |
| ០៩ | កោះកុង | ៩.០០០ | ៦៤,៣ |
| ១០ | ក្រចេះ | ៥៨.០០០ | ៩៣,៥ |
| ១១ | មណ្ឌលគិរី | ១១.០០០ | ៧៨,៦ |
| ១២ | ភ្នំពេញ | ២០.០០០ | ៩០,៩ |
| ១៣ | ព្រះវិហារ | ៣០.០០០ | ៧១,៤ |
| ១៤ | ព្រៃវែង | ២១៤.០០០ | ៩៩,៥ |
| ១៥ | ពោធិ៍សាត់ | ៦៣.០០០ | ៨០,៨ |
| ១៦ | រតនគិរី | ៣៦.០០០ | ៩២,៣ |
| ១៧ | សៀមរាប | ១០៧.០០០ | ៨២,៣ |
| ១៨ | ព្រះសីហនុ | ១០.០០០ | ៨៣,៣ |
| ១៩ | ស្ទឹងត្រែង | ២៦.០០០ | ១០០,០ |
| ២០ | ស្វាយរៀង | ៧៨.០០០ | ៨៥,៧ |
| ២១ | តាកែវ | ១៤៣.០០០ | ៩៥,៣ |
| ២២ | ឧត្ដរមានជ័យ | ៣៩.០០០ | ៨១,៣ |
| ២៣ | កែប | ៥.០០០ | ១០០,០ |
| ២៤ | ប៉ៃលិន | ៤.០០០ | ៥០,០ |
| ២៥ | ត្បូងឃ្មុំ | ១០០.០០០ | ៨១,៣ |




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

# ផែនទី ១.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត

**កម្ពុជា**

| | |
|---|---|
| ចំនួនគ្រួសារប្រកបរបរកសិកម្មសរុប | : ២.០៣៨.០០០ |
| ភាគរយនៃចំនួនគ្រួសារប្រកបរបរកសិកម្ម បានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) | : ១៧,២% |




តិចជាង ១ ក្នុងចំណោម ៥គ្រួសារដែលប្រកបរបរកសិកម្មនៅកម្ពុជាបានរាយការណ៍ពីឯកកម្មសិទ្ធិដោយបានចុះបញ្ជី។ ជិត ៥៧% នៃគ្រួសារប្រកបរបរកសិកម្មនៅខេត្តបន្ទាយមានជ័យ បានរាយការណ៍ពីឯកកម្មសិទ្ធិដោយបានចុះបញ្ជី ខណៈដែលនៅខេត្តតាកែវមានតែ ៤,៧% ប៉ុណ្ណោះ។

## កំណត់សម្គាល់

- ផ្ទៃទឹក

គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) (%)

- Not Available
- ០,១ - ១០,០
- ១០,១ - ២០,០
- ២០,១ - ៣០,០
- ៣០,១ - ៤០,០
- > ៤០,០

ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

តារាង ១.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី)

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្ម បានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) | គ្រួសារប្រកបរបរកសិកម្ម បានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) (%) |
|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ៦៣.០០០ | ៥៦,៨ |
| ០២ | បាត់ដំបង | ៦២.០០០ | ៤៤,៦ |
| ០៣ | កំពង់ចាម | ៦៩.០០០ | ៥០,០ |
| ០៤ | កំពង់ឆ្នាំង | ៦.០០០ | ៦,៧ |
| ០៥ | កំពង់ស្ពឺ | ១៤.០០០ | ១១,៧ |
| ០៦ | កំពង់ធំ | ៩.០០០ | ៧,៦ |
| ០៧ | កំពត | - | - |
| ០៨ | កណ្ដាល | - | - |
| ០៩ | កោះកុង | ៥.០០០ | ៣៥,៧ |
| ១០ | ក្រចេះ | ៤.០០០ | ៦,៥ |
| ១១ | មណ្ឌលគិរី | - | - |
| ១២ | ភ្នំពេញ | ២.០០០ | ៩,១ |
| ១៣ | ព្រះវិហារ | ១២.០០០ | ២៨,៦ |
| ១៤ | ព្រៃវែង | - | - |
| ១៥ | ពោធិ៍សាត់ | ១៤.០០០ | ១៧,៩ |
| ១៦ | រតនគិរី | ៣.០០០ | ៧,៧ |
| ១៧ | សៀមរាប | ២៣.០០០ | ១៧,៧ |
| ១៨ | ព្រះសីហនុ | ២.០០០ | ១៦,៧ |
| ១៩ | ស្ទឹងត្រែង | - | - |
| ២០ | ស្វាយរៀង | ១៣.០០០ | ១៤,៣ |
| ២១ | តាកែវ | ៧.០០០ | ៤,៧ |
| ២២ | ឧត្ដរមានជ័យ | ៩.០០០ | ១៨,៨ |
| ២៣ | កែប | - | - |
| ២៤ | ប៉ៃលិន | ៣.០០០ | ៣៧,៥ |
| ២៥ | ត្បូងឃ្មុំ | ២២.០០០ | ១៧,៩ |




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

# ២. ស្ថានភាពកម្មសិទ្ធិលើកសិដ្ឋានរបស់គ្រួសារប្រកបរបរកសិកម្ម

# ផែនទី ២.១៖ កម្មសិទ្ធិដីកសិកម្មផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត

**កម្ពុជា**

ចំនួនគ្រួសារប្រកបរបរកសិកម្មសរុប : ២.០៣៨.០០០

ភាគរយនៃគ្រួសារប្រកបរបរកសិកម្មមានកម្មសិទ្ធិដីផ្ទាល់ខ្លួន : ៩៧,៧%




គ្រួសារប្រកបរបរកសិកម្មស្ទើរតែទាំងអស់នៅកម្ពុជាធ្វើកសិកម្មលើដីដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ខេត្តដែលមានភាគរយនៃគ្រួសារប្រកបរបរកសិកម្មមានកម្មសិទ្ធិលើដីរបស់ខ្លួនទាបជាងគេគឺខេត្តប៉ៃលិន (៨៧,៥)។ ប្រហែល១/៣ នៃខេត្តទាំងអស់របស់កម្ពុជាមានអត្រាខ្ពស់ ៩៩%។

## កំណត់សម្គាល់

- ផ្ទៃទឹក

គ្រួសារប្រកបរបរកសិកម្មរាយការណ៍កម្មសិទ្ធិលើដីកសិកម្ម (%)

- ≤ ៩០,០
- ៩៣,១ - ៩៦,០
- ៩៦,១ - ៩៩,០
- > ៩៩,០

ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

តារាង ២.១៖ កម្មសិទ្ធិដីកសិកម្មផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្ម រាយការណ៍ កម្មសិទ្ធិលើដីកសិកម្ម | គ្រួសារប្រកបរបរកសិកម្ម រាយការណ៍ កម្មសិទ្ធិលើដីកសិកម្ម (%) |
|---|---|---:|---:|
| ០១ | បន្ទាយមានជ័យ | ១០៩.០០០ | ៩៨,២ |
| ០២ | បាត់ដំបង | ១៣១.០០០ | ៩៤,២ |
| ០៣ | កំពង់ចាម | ១៣៥.០០០ | ៩៧,៨ |
| ០៤ | កំពង់ឆ្នាំង | ៨៨.០០០ | ៩៨,៩ |
| ០៥ | កំពង់ស្ពឺ | ១២០.០០០ | ១០០,០ |
| ០៦ | កំពង់ធំ | ១១៧.០០០ | ៩៨,៣ |
| ០៧ | កំពត | ១០៩.០០០ | ៩៩,១ |
| ០៨ | កណ្ដាល | ១២៣.០០០ | ៩៣,២ |
| ០៩ | កោះកុង | ១៤.០០០ | ១០០,០ |
| ១០ | ក្រចេះ | ៦១.០០០ | ៩៨,៤ |
| ១១ | មណ្ឌលគិរី | ១៤.០០០ | ១០០,០ |
| ១២ | ភ្នំពេញ | ២០.០០០ | ៩០,៩ |
| ១៣ | ព្រះវិហារ | ៤២.០០០ | ១០០,០ |
| ១៤ | ព្រៃវែង | ២១៣.០០០ | ៩៩,១ |
| ១៥ | ពោធិ៍សាត់ | ៧៦.០០០ | ៩៧,៤ |
| ១៦ | រតនគិរី | ៣៩.០០០ | ១០០,០ |
| ១៧ | សៀមរាប | ១២៨.០០០ | ៩៨,៥ |
| ១៨ | ព្រះសីហនុ | ១១.០០០ | ៩១,៧ |
| ១៩ | ស្ទឹងត្រែង | ២៥.០០០ | ៩៦,២ |
| ២០ | ស្វាយរៀង | ៩០.០០០ | ៩៨,៩ |
| ២១ | តាកែវ | ១៤៩.០០០ | ៩៩,៣ |
| ២២ | ឧត្តរមានជ័យ | ៤៦.០០០ | ៩៥,៨ |
| ២៣ | កែប | ៥.០០០ | ១០០,០ |
| ២៤ | ប៉ៃលិន | ៧.០០០ | ៨៧,៥ |
| ២៥ | ត្បូងឃ្មុំ | ១២០.០០០ | ៩៧,៦ |




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

## ផែនទី ២.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត

**កម្ពុជា**

ចំនួនគ្រួសារប្រកបរបរកសិកម្មសរុប : ២.០៣៨.០០០

ភាគរយនៃចំនួនគ្រួសារប្រកបរបរកសិកម្ម ដែលបានជួលដីកសិកម្ម : ៤,៨%




តិចជាង ៥% នៃគ្រួសារប្រកបរបរកសិកម្មនៅកម្ពុជាបានជួលដីកសិកម្មពីអ្នកដទៃ។ គ្រួសារនៅក្នុងខេត្តភាគខាងលិចហាក់មានទំនោរជួលដីកសិកម្មច្រើនជាងតំបន់ផ្សេង ដោយក្នុងនោះខេត្តបាត់ដំបង ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យមានអត្រាលើសពី ១០%។

### កំណត់សម្គាល់

ផ្ទៃទឹក

គ្រួសារប្រកបរបរកសិកម្ម ដែលបានជួលដីកសិកម្ម (%)

- Not Available
- ០,១ - ៣,០
- ៣,១ - ៥,០
- ៥,១ - ៨,០
- > ៨,០

ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

តារាង ២.២៖ គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្ម រាយការណ៍ថា ជួលដីកសិកម្ម | គ្រួសារប្រកបរបរកសិកម្ម រាយការណ៍ថា ជួលដីកសិកម្ម (%) |
|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ៥.០០០ | ៤,៥ |
| ០២ | បាត់ដំបង | ២៤.០០០ | ១៧,៣ |
| ០៣ | កំពង់ចាម | ៧.០០០ | ៥,១ |
| ០៤ | កំពង់ឆ្នាំង | ២.០០០ | ២,២ |
| ០៥ | កំពង់ស្ពឺ | - | - |
| ០៦ | កំពង់ធំ | ៤.០០០ | ៣,៤ |
| ០៧ | កំពត | ៤.០០០ | ៣,៦ |
| ០៨ | កណ្ដាល | ១០.០០០ | ៧,៦ |
| ០៩ | កោះកុង | - | - |
| ១០ | ក្រចេះ | - | - |
| ១១ | មណ្ឌលគិរី | - | - |
| ១២ | ភ្នំពេញ | ៣.០០០ | ១៣,៦ |
| ១៣ | ព្រះវិហារ | - | - |
| ១៤ | ព្រៃវែង | ៨.០០០ | ៣,៧ |
| ១៥ | ពោធិ៍សាត់ | ២.០០០ | ២,៦ |
| ១៦ | រតនគិរី | - | - |
| ១៧ | សៀមរាប | ៨.០០០ | ៦,២ |
| ១៨ | ព្រះសីហនុ | - | - |
| ១៩ | ស្ទឹងត្រែង | - | - |
| ២០ | ស្វាយរៀង | ៣.០០០ | ៣,៣ |
| ២១ | តាកែវ | ៣.០០០ | ២,០ |
| ២២ | ឧត្ដរមានជ័យ | ៦.០០០ | ១២,៥ |
| ២៣ | កែប | - | - |
| ២៤ | ប៉ៃលិន | ១.០០០ | ១២,៥ |
| ២៥ | ត្បូងឃ្មុំ | ៥.០០០ | ៤,១ |




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

# ៣. ទំហំដីកសិកម្ម

# ផែនទី ៣.១៖ គ្រួសារដែលមានដីកសិកម្មតិចជាង ២ ហិកតា គិតជាភាគរយ បែងចែកតាមខេត្ត

**កម្ពុជា**

ចំនួនគ្រួសារប្រកបរបរកសិកម្មសរុប : ២.០៣៨.០០០

ភាគរយនៃគ្រួសារប្រកបរបរកសិកម្ម ដែលមានដីកសិកម្មតិចជាង ២ហិកតា : ៧១,៩%

ជិត ៧២% នៃគ្រួសារប្រកបរបរកសិកម្មនៅកម្ពុជា បានរាយការណ៍ថាមានដីកសិកម្មតិចជាង ២ហិកតា។ ភាគរយខ្ពស់បំផុតគឺនៅខេត្តកែប កោះកុង និងភ្នំពេញ រីឯភាគរយទាបបំផុតគឺនៅខេត្តឧត្តរមានជ័យ។ អត្រាលើសពី ៨០% ប្រមូលផ្ដុំនៅខេត្តភាគខាងត្បូងនៃប្រទេសកម្ពុជា។




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ។

តារាង ៣.១៖ គ្រួសារដែលមានដីកសិកម្មតិចជាង ២ ហិកតា

